ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
លេខៈ ០៥ អយក.សណន

# សេចក្តីណែនាំ
# ស្តីពី
# ការអនុវត្តកម្មវិធីត្រីវិស័យនៅតាមគ្រឹះស្ថានមធ្យមសិក្សា

ក្រសួងអប់រំ យុវជន និងកីឡា សហការជាមួយអង្គការសកម្មភាពសម្រាប់ការអប់រំនៅកម្ពុជា (KAPE) បានបង្កើតកម្មវិធីផ្តល់ប្រឹក្សាតាមប្រព័ន្ធអេឡិចត្រូនិច "ត្រីវិស័យ" (TreyVisay) ក្នុងគោលបំណងឱ្យសិស្សស្វ័យវាយតម្លៃអំពីបុគ្គលិកលក្ខណៈ មុខរបរ និងឈ្វេងយល់អំពីព័ត៌មានគ្រឹះស្ថានសិក្សានិងទីផ្សារការងារ។

ដើម្បីឱ្យសិស្សអនុវត្តកម្មវិធីត្រីវិស័យ នៅតាមគ្រឹះស្ថានសិក្សាប្រកបដោយប្រសិទ្ធភាព ក្រសួងអប់រំ យុវជន និងកីឡា សូមធ្វើការណែនាំដល់មន្ទីរអប់រំ យុវជន និងកីឡារាជធានី-ខេត្ត និងគ្រឹះស្ថានសិក្សាទាំងអស់ដូចខាងក្រោម៖

## ១. ភារកិច្ចរបស់មន្ទីរអប់រំ យុវជន និងកីឡារាជធានី-ខេត្ត

- ផ្សព្វផ្សាយឱ្យបានទូលំទូលាយដល់គ្រឹះស្ថានសិក្សាក្រោមឱវាទ ដើម្បីឱ្យសិស្សានុសិស្សចូលប្រើប្រាស់កម្មវិធីត្រីវិស័យប្រកបដោយប្រសិទ្ធភាព
- ណែនាំគ្រឹះស្ថានមធ្យមសិក្សាក្រោមឱវាទ រៀបចំផែនការអនុវត្តកម្មវិធីត្រីវិស័យ ឱ្យបានគ្រប់កម្រិតថ្នាក់
- ចូលរួមដោះស្រាយបញ្ហាប្រឈមផ្សេងៗ ជាមួយគ្រឹះស្ថានសិក្សា ក្នុងការប្រើប្រាស់កម្មវិធីត្រីវិស័យដោយស្មារតីទទួលខុសត្រូវខ្ពស់
- កៀរគរធនធាន និងដៃគូសហការ ដើម្បីគាំទ្រដំណើរការអនុវត្តកម្មវិធីត្រីវិស័យឱ្យមានប្រសិទ្ធភាព
- ពិនិត្យតាមដាន និងផ្តល់របាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំ អំពីការអនុវត្តកម្មវិធីត្រីវិស័យ នៅតាមគ្រឹះស្ថានសិក្សា ជូននាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ។

## ២. ភារកិច្ចរបស់គ្រឹះស្ថានសិក្សា

- រៀបចំផែនការណែនាំការអនុវត្តកម្មវិធីត្រីវិស័យដល់សិស្សានុសិស្សគ្រប់កម្រិតថ្នាក់
- ចាត់តាំងឱ្យមានអ្នកទទួលខុសត្រូវក្នុងការណែនាំ និងប្រើប្រាស់កម្មវិធីត្រីវិស័យដល់សិស្ស
- ចូលរួមដោះបញ្ហាប្រឈមផ្សេងៗ ក្នុងការប្រើប្រាស់កម្មវិធីត្រីវិស័យ ដោយស្មារតីទទួលខុសត្រូវខ្ពស់
- កៀរគរធនធានដៃគូសហការ ដើម្បីគាំទ្រដំណើរការអនុវត្តកម្មវិធីត្រីវិស័យឱ្យមានប្រសិទ្ធភាព
- រៀបចំរបាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំ អំពីការអនុវត្តកម្មវិធីត្រីវិស័យ ជូនមន្ទីរអប់រំ យុវជន និងកីឡារាជធានី-ខេត្ត។

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទៈ (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារៈ (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែលៈ info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh

## ៣. តួនាទីរបស់គ្រូទទួលបន្ទុកអនុវត្តកម្មវិធីត្រីវិស័យ

- រៀបចំផែនការប្រចាំឆ្នាំ ស្តីពីការផ្សព្វផ្សាយ និងណែនាំការប្រើប្រាស់កម្មវិធីត្រីវិស័យដល់សិស្សគ្រប់កម្រិតថ្នាក់
- អនុវត្តការផ្សព្វផ្សាយ និងណែនាំការប្រើប្រាស់កម្មវិធីត្រីវិស័យ
- សម្របសម្រួលក្នុងដំណើរការប្រើប្រាស់កម្មវិធីត្រីវិស័យដល់សិស្ស
- ណែនាំសិស្ស អំពីរបៀបដំឡើងកម្មវិធីត្រីវិស័យក្នុងទូរសព្ទឆ្លាតវៃ ឬកុំព្យូទ័របន្ទះ (Tablet) ពីក្នុង App Store ឬ Play Store
- ណែនាំរបៀបប្រើប្រាស់លម្អិតកម្មវិធីត្រីវិស័យ ដូចក្នុងឧបសម្ព័ន្ធជូនភ្ជាប់
- រៀបចំរបាយការណ៍ អំពីលទ្ធផលនៃការប្រើប្រាស់កម្មវិធីត្រីវិស័យរបស់សិស្ស ជូនគណៈគ្រប់គ្រងគ្រឹះស្ថានសិក្សា។

ក្រសួងសង្ឃឹមថា លោក លោកស្រីប្រធានមន្ទីរអប់រំ យុវជន និងកីឡារាជធានី-ខេត្ត គណៈគ្រប់គ្រងគ្រឹះស្ថានមធ្យមសិក្សា និងលោកគ្រូ អ្នកគ្រូទទួលបន្ទុកអនុវត្តកម្មវិធីត្រីវិស័យនៅតាមគ្រឹះស្ថានមធ្យមសិក្សាសាធារណៈទាំងអស់ ចូលរួមអនុវត្តតាមសេចក្តីណែនាំនេះឱ្យមានប្រសិទ្ធភាពដោយស្មារតីទទួលខុសត្រូវខ្ពស់។

ថ្ងៃ ច័ន្ទ ៤ កើត ខែ ផល្គុន ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២១

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

**កន្លែងទទួល៖**

- គ្រប់រដ្ឋបាលរាជធានី-ខេត្ត
- អគ្គនាយកដ្ឋានអប់រំ
- ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី «ដើម្បីជូនជ្រាបជាព័ត៌មាន»
- គ្រប់មន្ទីរអប់រំ យុវជន និងកីឡា រាជធានី-ខេត្ត «ដើម្បីមុខការ»
- កាលប្បវត្តិ
- ឯកសារ នាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ

# ត្រីវិស័យ

## បញ្ចូលគណនី

ឈ្មោះគណនី

លេខសម្ងាត់

ចូលគណនី

មិនទាន់មានគណនីមែនទេ? **បង្កើតគណនី**

ជំនាន់: 1.1